ស្មារតីសក្តិភូមិ

សេរីការ

ថ្មីៗនេះ លោក គង់ គាំ អតិតប្រធានគណបក្សសមរង្សី សួរជាសំណួរថា គាត់ជួយគណបក្សគ្រោះជាតិ ក្នុងនាមជាអ្វី ? កូនប្រុសរបស់គាត់ ដែលជាអ្នកដំណាងរាស្ត្រ ឆ្លើយតប ជាសំណើរមិនចំពោះថា គួរលោក សម រង្សី តែងតាំង ឪពុកលោក ជាអ្នកតំណាងកិត្តិយស នៃគណបក្សគ្រោះជាតិ ដើម្បី ១គាត់មានងារជាជ្លូវការ ក្នុងការបំពេញបេសកកម្ម ក្រប់សារពើដើម្បីគណបក្ស។ សំនួរ និងការស្នើនេះ ជា ស្មារតីសក្តិភូមិ (esprit féodal) ហើយក៏ជា ការបង្ហាញដែរ នៃ មានសិកភាព (mentalité) របស់ថ្នាក់ដឹកនាំកំពូល នៃបក្សគ្រោះជាតិ ចង់តែពាក់ងារជាកិត្តិយសនោះដែរ។ លោក គង់ គាំ គួរគាត់គិតទៅវិញថា បើគាត់ចង់សង្គ្រោះជាតិ មានចិត្តជាអ្នកស្នេហាជាតិ ឬជា អ្នកបំរើប្រជាពលរដ្ឋ វាជា កិត្តិយសដ៏ឧត្តុងឧត្តមណាស់ទៅហើយមិនចាំបាច់គាត់ ស្វែងរកងារ ជាជ្លូវការអ្វីផ្សេងទៀតនោះឡើយ។ បំរើជាតិ ក្នុងនាមជា កម្មិកសមាជិក (bénévolat) វាមានប្រយោជន៏ និងកិត្តិយស សំរាប់ លោក គង់ គាំ ជាង ក្នុងនាមលោក ជាអ្នកតំណាងកិត្តិយស ក្នុងស្មារតីសក្តិភូមិ។ តែលោក គង់ គាំ គាត់មិនអាចយល់បាន នូវខ្លឹមសារ នៃភាពផ្ទៃផ្ទរ ជា អ្នកស្នេហាជាតិបាននោះឡើយ ព្រោះទាំងស្មារតី និងសព៌ាង្គកាយ របស់គាត់ រាស់ជាសុខដុម នៅក្នុងប្រព័ន្ធ របបចោរម៉ន

(kleptocratie) ពីយូរយារមកហើយ ហើយសុភមង្គលអាត្មានេះ ដែលនាំអោយគាត់ មិនដែលបាននឹកឃើញធ្វើអភិវឌ្ឍន៍ នូវស្ការតីជាតិរបស់គាត់ម្តងណាឡើយ ទោះបីបុត្ររបស់គាត់ ធ្លាប់បានទទួលរងគ្រោះ នូវអំពើព្រៃផ្សៃ ពីសំណាក់របបផ្តាច់ការយ៉ាងណាក្តី។ ប្រតិកម្ម នៃការលាលែងពីដំណែង ប្រធានគណបក្សសមរង្សី និងបញ្ឍប់សកម្មភាពនយោបាយរបស់គាត់នៅពេលនោះ វាគ្រាន់តែជា ការភ័យខ្លាច នៃការសងសឹកបន្ថែមទៀតរបស់លោក ហ៊ុន សែន មកលើរូបគាត់តែប៉ុណ្ណោះ។

ស្ការតីសក្តិភូមិនេះ វាជា ក្អែលដុះស្ងួម នៃក្រុមអ្នកដឹកនាំ និងអ្នកនយោបាយខ្មែរសព្វថ្ងៃនេះ នាំគ្នាបង្កើត នូវប៉ាន ១ សំរាប់អោយយួនដុតខ្ទោចប្រជាជាតិខ្មែរ ព្រោះអ្នកទាំងនោះ មានរោគឆ្លួតប្រាំយ៉ាង គឺ ស្រី ស្រា ល្បែង យសស័ក្ត និងលុយ ដែលជា រិទ្ធភាព (ឧបសគ្ត) សំរាប់ ការពារជាតិ និងរក្សាសេចក្តីថ្លៃថ្នូរ ជា នរជន។ ពួកមនុស្សបែបនេះមិនអាចមាន ឧមា (paix) ក្នុងចិត្តបាននោះឡើយ ព្រោះ សេចក្តីលោភ វាជា ផ្ទូរជីវិតរបស់គាត់ នៅក្នុងមជ្ឈដ្ឋាន គ្មាន ខ្លឹមសារអប់រំ (base de l'éducation) នៃសីលធម៌ នៃមនុស្សជាតិ។